**The Royal Women's Hospital Information for Women**

**3. វិធីបង្ការកុំឲ្យមានផ្ទៃពោះ : the pill (ថ្នាំគ្រាប់)**

*ខែមេសា ឆ្នាំ 2004*

## 3. CONTRACEPTION: THE PILL

## ហេតុអ្វីបានជាប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ?

**ការបង្ការមិនឲ្យមានផ្ទៃពោះ គឺជាការចាំបាច់ បើអ្នកចង់ចៀសវាងផ្ទៃពោះដែលមិនចង់បាន និង ជំងឺកាមរោគ។**

រៀងរាល់ខែ អូវែរបស់ស្ត្រីផលិតពងមេជីវិតស្ត្រី។ នៅពេលដែលបុរសបញ្ចេញទឹកកាម ទឹកកាមនេះមានមេជីវិតបុរស រាប់លាន។ វាត្រូវការតែមេជីវិតបុរសនេះមួយប៉ុណ្ណោះ ដើម្បីចូលទៅបង្កាត់ក្នុងពងមេជីវិតស្ត្រី ហើយចាប់ផ្ដើមមានផ្ទៃ ពោះ។ បើគូស្រករធ្វើការរួមរ័កនឹងគ្នា (លិង្គនៅក្នុងរន្ធយោនី) ហើយគ្មានការប្រុងប្រយ័ត្នជាមុនទេនោះ ស្ត្រីមានលទ្ធភាព ខ្ពស់ក្នុងការមានផ្ទៃពោះ។ ការប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ អនុញ្ញាតឲ្យអ្នករួមរ័ក ហើយចៀសវាងការមានផ្ទៃពោះដោយ អចេតនា។

## ស្រោមអនាម័យ មិនមែនជាគំនិតល្អជានិច្ចទ្បើយ

ប្រទេសអូស្ត្រាលី មានជំងឺកាមរោគថ្មីជាង 20 000 ក្នុងមួយឆ្នាំៗ។ ជំងឺកាមរោគទូទៅបំផុតគឺ chlamydia ដែលអាច ធ្វើឲ្យមិនអាចមានកូនបាន បើទុកចោលមិនព្យាបាលទេនោះ។ ស្រោមអនាម័យគឺជាការការពារប្រសើរបំផុតរបស់អ្នកទល់ នឹងជំងឺកាមរោគ។ បើអ្នកប្រើស្រោមអនាម័យនិងប្រេងធ្វើពីជាតិទឹក នៅរាល់ពេលដែលអ្នករួមភេទ អ្នកនឹងមានឱកាស តិចក្នុងការឆ្លង HIV/AIDS និងជំងឺកាមរោគ (STIs)។

## ថ្នាំគ្រាប់ (The Pill) បង្ការកុំឲ្យមានផ្ទៃពោះ

ថ្នាំគ្រាប់បង្ការមិនឲ្យមានផ្ទៃពោះសំរាប់លេប មានពីរប្រភេទ។ ថ្នាំគ្រាប់គួបផ្សំគ្នា មានអ័រម៉ូនពីរ ហើយបញ្ឈប់កុំឲ្យអូវ៉ែរ បញ្ចេញពងមេជីវិតស្ត្រីជារៀងរាល់ខែ។ ថ្នាំគ្រាប់មានតែ progestogen ប៉ុណ្ណោះ (Mini Pill) មានអ័រម៉ូនតែមួយ ប៉ុណ្ណោះ ហើយបំពេញមុខងារដោយផ្លាស់ប្ដូរទឹករំអិលនៅត្រង់មាត់ទ្វារចូលរបសស្បូន ដើម្បីកុំឲ្យមេជីវិតបុរសអាចចូល ទៅបាន សំរាប់បង្កាត់ពងមេជីវិតស្ត្រី។

ថ្នាំគ្រាប់មានតែ progestogen ប៉ុណ្ណោះ មានប្រសិទ្ធភាពតិចជាងថ្នាំគ្រាប់គួបផ្សំបន្តិច។

## ថ្នាំគ្រាប់គួបផ្សំ

### ប្រសិទ្ធភាពរបស់វា

ថ្នាំគ្រាប់គួបផ្សំ មានប្រសិទ្ធភាពប្រហែល 98% ***បើប្រើត្រឹមត្រូវ***។ ប្រសិទ្ធភាពត្រូវបានកាត់បន្ថយ ដោយសារការលេប ថ្នាំនេះមិនទៀងទាត់ រាករូសនិងក្អួត ហើយដោយសារថ្នាំផ្សះខ្លះ ឬ ថ្នាំផ្សេងទៀត។ អ្នកគ្មានការការពារទល់នឹងការមាន ផ្ទៃពោះទេ របូតទាល់តែអ្នកបានលេបថ្នាំអ័រម៉ូនអស់ពេលប្រាំពីរថ្ងៃ។ ថ្នាំគ្រាប់នេះមិនបង្កនូវភាពមិនអាចមានផ្ទៃពោះទេ។

**គុណសម្បត្តិ**

- ការធ្លាក់ឈាមជាទៀងទាត់ ដោយមានការធ្លាក់ឈាមកាន់តែតិចទៅ
- ជាញឹកញយ រោគមុនមានភាពប្រសើរឡើង
- ភាពកាន់តែប្រសើរ ឬ ការបាត់បង់នៃ PMS (រោគសញ្ញាមុនពេលមានរដូវ) ដែលអាចបណ្តាលឲ្យមានរោគសញ្ញាមិនសុខស្រួល និង ការផ្លាស់អារម្មណ៍យ៉ាងរហ័ស នៅនឹងពេលប៉ុន្មានថ្ងៃមុនពេលចាប់ផ្តើមមានរដូវ។
- 

**គុណវិបត្តិ**

- ស្រៀវដោះ ចង្អោរ(អារម្មណ៍មិនស្រួលខ្លួន) និងការធ្លាក់ឈាមភ្លាម សំខាន់នៅក្នុងពេលពីរបីខែដំបូង ក្រោយពីលេបថ្នាំគ្រាប់នេះ
- ថ្នាំគ្រាប់នេះអាចបណ្តាលឲ្យឡើងទម្ងន់ខ្លះ ប្តូរអារម្មណ៍យ៉ាងរហ័ស ឬ ការបាត់បង់ចំណង់រួមរ័កចំពោះស្ត្រីខ្លះ
- បញ្ហាសុខភាពដ៏កំរ។

**លទ្ធភាពគ្រោះថ្នាក់ដល់សុខភាព**

បញ្ហាសុខភាពធ្ងន់ធ្ងរដោយសារថ្នាំគ្រាប់នេះ កំរកើតមានណាស់។ ការជក់បារីបង្កើនលទ្ធភាពនៃផលប៉ះពាល់មានគ្រោះថ្នាក់។ ថ្នាំគ្រាប់នេះមិនសក្តិសមសំរាប់ស្ត្រីដែលមានស្ថានភាពដូចតទៅនេះ :

- ប្រកាំងនៅកណ្តាលក្បាល
- ប្រវត្តិនៃការកកឈាម
- បញ្ហាថ្លើម
- ការធ្លាក់ឈាមយោនីមិនធម្មតា។

## ថ្នាំគ្រាប់មានតែ Progestogen ប៉ុណ្ណោះ (POP) ឬ ថ្នាំ Mini Pill

ថ្នាំគ្រាប់មានតែ progestogen ប៉ុណ្ណោះ (POP) ឬ Mini Pill មានអ័រម៉ូនតែមួយគត់របស់ស្ត្រី។ អ័រម៉ូន progestogen ធ្វើឲ្យទឹករំអិលនៅនឹងកស្បូន រឹតតែខាប់ឡើង។ បន្ទាប់មក ទឹករំអិលនេះក្លាយជាឆ្នុកមួយ ហើយបង្ការមិនឲ្យមេជីវិតបុរសចូលទៅក្នុងស្បូន និងមិនឲ្យធ្វើដំណើរទៅកាន់ដៃស្បូនដើម្បីបង្កាត់ពងមេជីវិតស្ត្រីឡើយ។ ថ្នាំគ្រាប់នេះមានប្រសិទ្ធភាព 95 ភាគរយ។

ចំពោះស្ត្រីភាគច្រើន ថ្នាំ mini pill នឹងមិនបង្ការស្ត្រីទាំងនោះកុំឲ្យមានដំណើរមានរដូវធម្មតានោះឡើយ។

ត្រូវលេបថ្នាំ mini pill ជារៀងរាល់ថ្ងៃ ដោយមិនឈប់សំរាកឡើយ។ នៅពេលចាប់ផ្តើមប្រើថ្នាំ POP អ្នកគួរប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះជាជំនួយ (ឧទាហរណ៍: ស្រោមអនាម័យ) រយ:ពេល 48 ម៉ោង។ វាជាការសំខាន់ណាស់ក្នុងការចៀសវាងការយឺតជាងបីម៉ោង នៅពេលលេបថ្នាំ POP ។

ថ្នាំនេះសក្តិសមសំរាប់ស្ត្រីដែលឲ្យកូនបៅដោះ ហើយអាចលេបតទៅទៀត នៅពេលដែលទារកញ៉ាំចំណីរឹង។

## ការលេបថ្នាំគ្រាប់

**សូមចងចាំថា ត្រូវ :**

- លេបថ្នាំមួយគ្រាប់ ក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃ
- លេបថ្នាំនីមួយៗនៅគ្រាដដែល ជារៀងរាល់ថ្ងៃ ឬ នៅពេលកៀកគ្នាទៅតាមលទ្ធភាព
- បើអ្នកភ្លេចលេបថ្នាំ ត្រូវលេបវាភ្លាមនៅពេលដែលអ្នកនឹកឃើញ ហើយលេបថ្នាំបន្ទាប់ពីនោះ នៅពេលធម្មតានៃថ្ងៃបន្ទាប់មកទៀត

ភាពអាចមានផ្ទៃពោះអាចវិលមកវិញ ហើយអ្នកអាចមានផ្ទៃពោះ បើ :

- អ្នកលេបថ្នាំយឺតជាងពេលធម្មតា លើសពី12 ម៉ោង
- អ្នកឈប់លេបថ្នាំ ដោយគ្មានវិធីបង្ការកុំឲ្យមានផ្ទៃពោះតាមទំរង់ផ្សេងទៀត។

**ពេលដែលអ្នកត្រូវការកិច្ចការពារទល់នឹងការមានផ្ទៃពោះ :**

- ក្នុងអម្លុងកញ្ចប់ដំបូង រហូតទាល់តែបានលេបថ្នាំអ័រម៉ូនទីប្រាំពីរ
- បើអ្នកក្អួត ឬ រាករូស
- នៅពេលលេបជាមួយថ្នាំផ្សេងទៀត ដែលអាចមានផលប៉ះពាល់ការស្រូបចូលនៃថ្នាំគ្រាប់នេះ ឧទាហរណ៍: ថ្នាំផ្សះ
- នៅពេលដែលអ្នកបានភ្លេចលេបថ្នាំមួយគ្រាប់ ឬ លេបថ្នាំយឺតជាងពេលធម្មតា លើសពី 12 ម៉ោង

នៅគ្រាទាំងនេះ ត្រូវបន្តលេបថ្នាំរហូតដល់បញ្ចប់កញ្ចប់របស់អ្នក ប៉ុន្តែត្រូវប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះតាមទំរង់ផ្សេងទៀត (ឧទាហរណ៍: ស្រោមអនាម័យ) រហូតទាល់តែបានលេបថ្នាំអ័រម៉ូនប្រាំពីរគ្រាប់ជាប់គ្នាបន្ថែមទៀត។

**ប៉ុន្តែបើ**ពេលប្រាំពីរថ្ងៃទាំងនេះ ចូលទៅដល់ពេលបញ្ចប់កញ្ចប់របស់អ្នក សូមកុំលេបថ្នាំអសកម្មទាំងពីរគ្រាប់នេះ ហើយចាប់ផ្តើមថ្នាំអ័រម៉ូននៅក្នុងកញ្ចប់បន្ទាប់វិញ។ បើអ្នកមិនដឹងច្បាស់ថាថ្នាំមួយណាដែលជាថ្នាំអសកម្ម ចូរសួរវេជ្ជបណ្ឌិត របស់អ្នក ឬ ទូរស័ព្ទទៅកាន់ Choices Clinic (គ្លីនិកជំរើស) អគារ Emergency (គ្រាអាសន្ន) Women’s Health Information Centre [មជ្ឈមណ្ឌលពត៌មានសុខភាពរបស់ស្ត្រី] (លេខនៅខាងចុងប័ណ្ណពត៌មាននេះ)។

## ថ្នាំគ្រាប់គ្រាអាសន្ន (ស្គាល់កាលពីគ្រាមុនថា Morning After Pill [ថ្នាំគ្រាប់នៅពេលព្រឹក បន្ទាប់])

### ថ្នាំគ្រាប់គ្រាអាសន្ន មានលក់នៅតាមឱសថស្ថាន ដោយមិនចាំបាច់មានវេជ្ជបញ្ជាឡើយ។

បើអ្នកមិនប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះទេ ហើយអ្នកបានរួមភេទនៅពេលដែលអ្នកគ្មានផែនការ ឬ រហែកស្រោមអនាម័យ ហើយអ្នកមិនចង់មានផ្ទៃពោះ នោះអ្នកអាចលេបថ្នាំគ្រាប់គ្រាអាសន្ន។ ថ្នាំគ្រាប់គ្រាអាសន្នរឹតតែមានប្រសិទ្ធភាព បើអ្នកលេបវាកាន់តែរហ័សនោះ។ អ្នកត្រូវចាប់ផ្តើមលេបថ្នាំគ្រាប់គ្រាអាសន្នក្នុងរង្វង់ពេលបីថ្ងៃ (72 ម៉ោង) បន្ទាប់ពីរួមភេទគ្មានវិធីការពារមក។ **យ៉ាងណាមិញ វារឹតតែមានប្រសិទ្ធភាព បើអ្នកលេបវាឲ្យកាន់តែរហ័ស។**

**តើអ្នកប្រើវាយ៉ាងណាដែរ?**

វិធីទូទៅបំផុតនៃវិធីបង្ការកុំឲ្យមានផ្ទៃពោះគ្រាអាសន្ន មានថ្នាំគ្រាប់ពីរគ្រាប់ផ្សេងគ្នា ដែលត្រូវលេបនៅពេលចន្លោះគ្នាចំនួន 12 ម៉ោង។ វិធីនេះបង្ការការមានផ្ទៃពោះដែលរំពឹងថានឹងមាន ចំនួនប្រហែល 85% ។

មានវិធីបង្ការកុំឲ្យមានផ្ទៃពោះគ្រាអាសន្នផ្សេងទៀតដែលមានថ្នាំគ្រាប់បង្ការកុំឲ្យមានផ្ទៃពោះគួបផ្សំច្រើន។ គេមិនស្នើឲ្យប្រើថ្នាំទាំងនេះតទៅទៀតទេ ដោយសារតែវាមិនសូវមានប្រសិទ្ធភាព ហើយមានផលវិបាកច្រើនជាង។ វិធីបង្ការកុំឲ្យមានផ្ទៃពោះគ្រាអាសន្នទាំងអស់ រឹតមានប្រសិទ្ធភាព បើលេបវារឹតតែរហ័សឡើង នៅបន្ទាប់ពីរួមភេទហើយ។

វាជាការសំខាន់ណាស់ក្នុងការកត់សំគាល់ថា មិនគួរប្រើថ្នាំគ្រាប់គ្រាអាសន្នធ្វើជាវិធីបង្ការកុំឲ្យមានផ្ទៃពោះតទៅទៀតទេ។ វាគ្មានប្រសិទ្ធភាពដូចថ្នាំគ្រាប់ឡើយ។

**លទ្ធភាពនៃផលវិបាក**

ផលវិបាក មិនមែនធម្មតាទេ ប៉ុន្តែស្ត្រីខ្លះអាចស្រៀវដោះ ឬ ឈឺក្បាល។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women’s Health Information Centre (RWH)**
(03) 834 304
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au
http://www.thewomens.org.au

## ប័ណ្ណពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត : http://www.thewomens.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ RWH ផ្តល់ឲ្យអ្នកនូវប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះផ្សេងទៀតផងដែរ។ សូមសួររក :

ទី 1 *វិធីបង្ការកុំឲ្យមានផ្ទៃពោះ ជំរើសរបស់អ្នក*
ទី 2 *ស្រោមអនាម័យ និង ស្រោម Diaphragms*
ទី 4 *Depo Provera – ការចាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ*
ទី 5 *Implanon – ការវះផ្សាំបង្ការកុំឲ្យមានផ្ទៃពោះ*
ទី 6 *IUD (Intra Uterine Device)[ឧបករណ៍ដាក់ក្នុងស្បូន]*

**ពត៌មានខ្លះនៅក្នុងប័ណ្ណពត៌មាននេះ គឺផ្អែកទៅលើប័ណ្ណពត៌មាន *Basic Facts About Contraception* (*ហេតុការណ៍គោលការណ៍អំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ*) ដោយ FPA Health**

មិនត្រូវផលិតឡើងវិញសំរាប់គោលបំណងលក់ដូរ ដោយគ្មានការអនុញ្ញាតរបស់ FPA Health និង Royal Women’s Hospital ឡើយ។